# មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី

## កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍សហគ្រិនស្ត្រី តាមប្រព័ន្ធអនឡាញ

## ព័ត៌មានទូទៅ

| | |
|---|---|
| **ឈ្មោះគម្រោង៖** | **កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍សហគ្រិនស្ត្រី** តាមប្រព័ន្ធអនឡាញ |
| **ដឹកនាំគម្រោង៖** | ក្រសួងកិច្ចការនារី និង ESCAP |
| **ទីតាំងអនុវត្ត៖** | រាជធានីភ្នំពេញ (តាមប្រព័ន្ធអនឡាញ) |
| **ប្រើប្រាស់ភាសា៖** | ខ្មែរ |
| **រយៈពេល៖** | ចាប់ពីខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ |
| **ក្រុមគោលដៅ៖** | ស្ត្រីនៅជនបទ និងតំបន់ទីក្រុង |

## ១. សេចក្តីផ្តើម

ក្រសួងកិច្ចការនារី (MoWA) មានចក្ខុវិស័យ ធានាឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិស្មើគ្នា ស្របតាមច្បាប់ ជាពិសេសស្ត្រីនិងក្មេងស្រី ទទួលបានសុវត្ថិភាពផ្ទាល់ខ្លួន ព្រមទាំងអាចចូលរួមយ៉ាងពេញលេញនៅក្នុងកិច្ចការសង្គម មានភាពអង់អាចនិងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតនិងគ្រប់វិស័យ ដោយស្មើភាពគ្នាជាមួយបុរសនិងក្មេងប្រុស ដើម្បីធានាបាននូវភាពម្ចាស់លើខ្លួនឯងនិងមានសុខមាលភាពពេញលេញនៅក្នុងគ្រួសារ និងសង្គមជាតិ។ ក្រសួងកិច្ចការនារី មានបេសកម្មក្នុងការដឹកនាំ ភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ននិងដៃគូពាក់ព័ន្ធ ក្នុងដំណើរឆ្ពោះទៅសម្រេចសមភាពយេនឌ័រនិងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី និងក្មេងស្រីគ្រប់រូបភាពក្នុងសង្គម ។

ដូចបានកំណត់នៅក្នុង**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣** ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចនិងការអភិវឌ្ឍភាពជាសហគ្រិនរបស់ស្ត្រី ជាផ្នែកសំខាន់មួយ ដើម្បីឈានទៅរកសមភាពយេនឌ័រនៅកម្ពុជា។ នៅក្នុងឆ្នាំ២០២១នេះ ស្ថិតក្រោមក្របខ័ណ្ឌនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី របស់ក្រសួងកិច្ចការ-នារី បានសហការជាមួយគណៈកម្មាធិការទទួលបន្ទុកសេដ្ឋកិច្ចនិងសង្គមសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) របស់អង្គការសហប្រជាជាតិ បង្កើតភាពជាដៃគូជាមួយសហគ្រាសសង្គម *ស៊ី អ៊ិនវេសមិន* ដែលជាសហគ្រាសសង្គម ដើម្បីសម្របសម្រួលនិងរៀបចំវគ្គបណ្តុះបណ្តាល និងសកម្មភាពនានាសម្រាប់ការអភិវឌ្ឍសហគ្រិនស្ត្រីចំនួន១០៥នាក់ ទាំងនៅជនបទនិងទីក្រុង ។

## ២. គោលបំណង

អភិវឌ្ឍន៍ជំនាញដល់សហគ្រិននិងអាជីវករស្ត្រី ចំនួន១០៥នាក់ ទាំងនៅជនបទនិងទីក្រុង ស្របតាមក្របខណ្ឌនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រីរបស់ក្រសួងកិច្ចការនារី ។

## ៣. មានកម្មវិធីអ្វីខ្លះ?

**កម្មវិធី ទី១៖** **ថ្នាលអភិវឌ្ឍន៍អាជីវកម្មកម្រិតមូលដ្ឋានដល់សហគ្រិនស្ត្រី** ១៥នាក់ រយៈពេល១០ថ្ងៃ ចាប់ពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០២១ ។

**កម្មវិធី ទី២៖** ***វគ្គបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងឌីជីថលដល់សហគ្រិនស្ត្រី*** ចំនួន៩០នាក់ រយៈពេល៣ថ្ងៃ នៅអំឡុងខែសីហា និងតុលា ។

## ៤. តើកម្មវិធីនីមួយៗ នឹងសិក្សាអំពីអ្វីខ្លះ និងអ្នកណាខ្លះអាចចូលរួមបាន?

***កម្មវិធីទី១៖ ថ្នាលអភិវឌ្ឍន៍អាជីវកម្មកម្រិតមូលដ្ឋានដល់សហគ្រិនស្ត្រី***

រយៈពេល១០ថ្ងៃ ***នៅចន្លោះពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០២១***

| សិក្ខាសាលា | ប្រធានបទ និងខ្លឹមសាររបស់ថ្នាល |
|---|---|
| ១ | ទិដ្ឋភាពទូទៅនៃកម្មវិធី និងគោលគំនិតអំពីយេនឌ័រ និងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី |
| ២ | ការរៀបចំគោលដៅ និងផែនការសកម្មភាពអាជីវកម្ម |
| ៣ | មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន |
| ៤ | ការគ្រប់គ្រងសាច់ប្រាក់អាជីវកម្មនិងកត់ត្រាបញ្ជីចំណូលចំណាយ |
| ៥ | គំរូអាជីវកម្ម Canvas និងការរក្សាអតិថិជន |
| ៦ | ការគ្រប់គ្រងទំព័រហ្វេសប៊ុកប្រកបដោយប្រសិទ្ធភាព |
| ៧ | របៀបប្រើប្រាស់ទូរស័ព្ទដៃឲ្យមានប្រសិទ្ធភាព |
| ៨ | ហិរញ្ញវត្ថុអាជីវកម្មមូលដ្ឋាននិងដំណើរទស្សនកិច្ចអាជីវកម្ម |
| ៩ | ប្រាក់ដែលទទួលបានមកវិញពីការវិនិយោគ និងការព្យាករណ៍លំហូរសាច់ប្រាក់ |
| ១០ | ការគ្រប់គ្រងខ្លួនឯងនិងបញ្ចប់ការសិក្សា |

### សម្រាប់ថ្នាលនេះ អ្នកណាខ្លះ អាចចូលរួម?

- ជាសហគ្រិន ឬអាជីវករស្ត្រី (ស្ត្រីមានពិការភាពត្រូវបានលើកទឹកចិត្តឱ្យចូលរួម)
- មានអាជីវកម្មផ្ទាល់ខ្លួន កម្រិតមីក្រូ តូច មធ្យម (ដែលគ្រប់គ្រងមនុស្សចាប់ពី ២នាក់ឡើងទៅ)
- មានទីតាំងអាជីវកម្មនៅកម្ពុជា (ភ្នំពេញ ឬបណ្តាខេត្តនានា)
- ប្តេជ្ញាចិត្ត ចូលរៀនទៀងទាត់ រយៈពេល២ថ្ងៃ ក្នុងមួយខែ សម្រាប់រយៈពេល៥ខែ (ខែសីហា ដល់ខែធ្នូ ឆ្នាំ២០២១)

- មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការពង្រឹងអាជីវកម្មរបស់ខ្លួន និងបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋផ្សេងៗទៀត។

***កម្មវិធី ទី២៖ វគ្គបណ្តុះបណ្តាលអក្ខរកម្មហិរញ្ញវត្ថុ និងឌីជីថល*** រយៈពេល ៣ ថ្ងៃ

| សិក្ខាសាលា | ប្រធានបទ |
|---|---|
| ១ | **អក្ខរកម្មហិរញ្ញវត្ថុអាជីវកម្ម** |
| ២ | **អក្ខរកម្មហិរញ្ញវត្ថុ៖ អាជីវកម្ម** |
| ៣ | **ការគ្រប់គ្រងទំព័រហ្វេសប៊ុកប្រកបដោយប្រសិទ្ធភាព** |

**សម្រាប់វគ្គនេះ អ្នកណាខ្លះ អាចចូលរួម?**

- ជាសហគ្រិន ឬអាជីវករស្ត្រី (ស្ត្រីមានពិការភាពត្រូវបានលើកទឹកចិត្តឱ្យចូលរួម)
- មានអាជីវកម្មផ្ទាល់ខ្លួន កម្រិតមីក្រូ តូច មធ្យម (ដែលគ្រប់គ្រងមនុស្សចាប់ពី ២នាក់ឡើងទៅ)
- មានទីតាំងអាជីវកម្មនៅកម្ពុជា (ភ្នំពេញ ឬតាមបណ្តាខេត្តណាមួយ)
- ប្តេជ្ញាចិត្តខ្ពស់ ក្នុងការចូលរៀនទៀងទាត់ រយៈពេល៣ថ្ងៃ។
- មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការពង្រឹងអាជីវកម្ម និងបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋផ្សេងៗទៀតនៅប្រទេសកម្ពុជា។

## ៥. ហេតុអ្វីបានជាអ្នកគួរចូលរួម

- ទទួលបានចំណេះដឹងបន្ថែមក្នុងការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន
- ទទួលបានឱកាសក្នុងការចូលរួមវគ្គបណ្តុះបណ្តាលជាមួយអ្នកជំនាញ
- ទទួលបានការបង្វឹកពីអ្នកជំនាញលើអាជីវកម្មរបស់ខ្លួន
- ពង្រឹង និងពង្រីកអាជីវកម្មរបស់អ្នក
- ទទួលបានវិញ្ញាបនបត្របញ្ជាក់ពីការចូលរួម។

## ព័ត៌មានសម្រាប់ការចុះឈ្មោះ

ចុះឈ្មោះនៅទីនេះ ដោយគ្រាន់តែធ្វើការចូលទៅកាន់តំណភ្ជាប់នេះដើម្បីធ្វើការបំពេញ។

https://forms.gle/3gFAswCHacY7pDi97។

ក្រុមការងារនឹងទំនាក់ទំនងសម្រាប់តែអ្នកចូលសម្ភាសន៍តែប៉ុណ្ណោះ។

**ផុតកំណត់ទទួលពាក្យថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១**

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

- ០១២ ៩០០ ៣៣៧/០១១ ៨៣៧ ៣៨៣
- mowa.edd@gmail.com